**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩១៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សម្រាប់សភាពាណិជ្ជកម្មខេត្តសៀមរាប អាណត្តិទី១ លើកទី២

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តសៀមរាប

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀប ចំការបោះឆ្នោតសភាពាណិជ្ជកម្ម

-បានឃើញកំណត់ហេតុ ស្តីពីលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មខេត្តសៀមរាប កាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១១

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា១ :** ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តសៀមរាប ចំនួន ១៥រូប សម្រាប់អាណត្តិទី១ លើកទី២ ដូចខាងក្រោម:

| | | |
|---|---|---|
| ១-លោក **ផេង គង់** | ៦-លោក **ប៊ុន ហៃ** | ១១-លោកស្រី **អេង សុខហ្គិច** |
| ២-លោកស្រី **អ៊ឹង ស៊ីតាតសុគន្ធារី** | ៧-ឧកញ៉ា **មាស ហាន** | ១២-លោក **វ៉ា គ្រី** |
| ៣-លោក **តាន់ ប៊ុនចេង** | ៨-លោក **សុខ ធីថា** | ១៣-លោកស្រី **ថៃ ធានី** |
| ៤-លោក **ហ៊ិន មុន្នីវណ្ណា** | ៩-លោក **ហ៊ុយ គៀង** | ១៤-លោក **កែណែម វីដាណូ** |
| ៥-លោក **ប៊ុន ម៉េង** | ១០-លោក **ហួ សៀកផេង** | ១៥-លោកស្រី **ថៃ ស៊ីណែម** |

**មាត្រា២ :** ទទួលស្គាល់លោកស្រី **អ៊ឹង ស៊ីតាតសុគន្ធារី** ជាប្រធានសភាពាណិជ្ជកម្មខេត្តសៀមរាប។

**មាត្រា៣ :** ទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិរបស់សភាពាណិជ្ជកម្មខេត្តសៀមរាប ដែលមានសមាសភាព ដូចខាងក្រោម:

| | |
|---|---|
| ១-លោក **ផេង គង់** | ប្រធានកិត្តិយសសភាពាណិជ្ជកម្មខេត្តសៀមរាប |
| ២-លោកស្រី **អ៊ឹង ស៊ីតាតសុគន្ធារី** | ប្រធានសភាពាណិជ្ជកម្មខេត្តសៀមរាប |
| ៣-លោក **តាន់ ប៊ុនចេង** | សមាជិក |
| ៤-លោក **ហ៊ិន មុន្នីវណ្ណា** | សមាជិក |
| ៥-លោក **ប៊ុន ម៉េង** | សមាជិក |
| ៦-លោក **ប៊ុន ហៃ** | សមាជិក |
| ៧-ឧកញ៉ា **មាស ហាន** | សមាជិក |
| ៨-លោក **សុខ ធីថា** | សមាជិក |
| ៩-លោក **ហ៊ុយ គៀង** | សមាជិក |
| ១០-លោក **ហួ សៀកផេង** | សមាជិក |
| ១១-លោកស្រី **អេង សុខហ្គិច** | សមាជិក |
| ១២-លោក **វ៉ា គ្រី** | សមាជិក |
| ១៣-លោកស្រី **ថៃ ធានី** | សមាជិក |
| ១៤-លោក **កែណែម វីដាណូ** | សមាជិក |
| ១៥-លោកស្រី **ថៃ ស៊ីណែម** | សមាជិក |

**មាត្រា៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តសៀមរាប ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងសាមីខ្លួន ដូចមានចែងក្នុង

មាត្រា១ មាត្រា២ និងមាត្រា៣ ត្រូវ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ៧ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសុំចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល:</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-សាលារាជធានី-ខេត្ត

-សភាពាណិជ្ជកម្មកម្ពុជា

-ដូចមាត្រា៥

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ